ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ៨៤៥ សសណា ប.ស្ក

# សេចក្ដីប្រកាសព័ត៌មាន
# លើការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
# "សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា"

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន បណ្ដាញសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល សិស្ស និស្សិត និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា ក្រសួងបរិស្ថាន បានផ្ដួចផ្ដើមគំនិត និងរៀបចំជា **"សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា"** ដំបូងគេ និង ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុង**វេទិកាកេសរកូលជាតិលើកទី២ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នៅអគារខេមរានី សហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ** ក្រោមអធិបតីភាព **ឯកឧត្ដម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

សៀវភៅគ្រឿងទេសនេះបានរៀបចំឡើង ដើម្បីកំណត់អត្តសញ្ញាណ ចងក្រងទុកជាឯកសារ អំពីលក្ខណៈជីវសាស្ត្រ រូបសាស្ត្រ សារប្រយោជន៍ ចំណេះដឹងជាប្រពៃណី និងរបៀបនៃការប្រើប្រាស់ រុក្ខជាតិគ្រឿងទេសនៅកម្ពុជា ដែលប្រជាជនតែងតែអនុវត្តតាំងពីដូនតា សម្រាប់ធ្វើជាគ្រឿងផ្សំក្នុង ម្ហូបអាហារប្រចាំថ្ងៃ និងជាឱសថថែរក្សាសុខភាព និងព្យាបាលជំងឺ។

**សៀវភៅមគ្គុទេសក៍ស្ដីពីគ្រឿងទេសនៅប្រទេសកម្ពុជា** នឹងមានចែកជូនដល់សាធារណជន បណ្ដាញសារព័ត៌មាន តំណាងស្ថាប័ន និងសិស្សនិស្សិតដែលអញ្ជើញចូលរួមក្នុងវេទិកាកេសរកូលជាតិ លើកទី២ និងទស្សនាពិព័រណ៍កេសរកូល នៅអគារខេមរានី សហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ចាប់ពីម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ១៧:០០នាទី។

អាស្រ័យហេតុនេះ សូមសាធារណជន បណ្ដាញសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល សិស្ស និស្សិត និងអ្នកពាក់ព័ន្ធទាំងអស់ជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមដោយរីករាយ។

ថ្ងៃ ច័ន្ទ ៩កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០២២

*ព័ត៌មានបន្ថែម សូមទាក់ទង៖*
*លោក សេង វឌ្ឍនា*
*លេខទូរសព្ទ៖ ០១២ ៥១៩ ២៧៩*

អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០